ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ...ធ៨.៥..០២១..៩៥០.សរឥណ...

ថ្ងៃ សុក្រ ១២រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២១

# សេចក្ដីជូនដំណឹង

## ស្ដីពី

## ការប្រើប្រាស់សេវាធនាគារតាមប្រព័ន្ធអេឡិចត្រូនិក (Online Banking System - OBS)

ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនដំណឹងដល់ ក្រសួង-ស្ថាប័នរដ្ឋ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលប្រើប្រាស់សេវាធនាគារតាមប្រព័ន្ធអេឡិចត្រូនិក (OBS) ឱ្យបានជ្រាបថា ធនាគារជាតិនៃកម្ពុជា បានធ្វើបច្ចុប្បន្នកម្មសេវាធនាគារតាមប្រព័ន្ធអេឡិចត្រូនិក (OBS) រួមទាំងលក្ខខណ្ឌ និងខថែង ស្ដីពីការប្រើប្រាស់សេវានេះ ដែលអាចអនុញ្ញាតឱ្យធ្វើប្រតិបត្តិការផ្ទេរប្រាក់បន្ថែម ដូចខាងក្រោម៖

១). ប្រតិបត្តិការផ្ទេរប្រាក់ រវាងគណនីចរន្តរបស់អ្នកទទួលសេវាតែមួយ នៅស្នាក់ការកណ្ដាលធនាគារជាតិនៃកម្ពុជា និងនៅសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត និង

២). ប្រតិបត្តិការផ្ទេរប្រាក់ រវាងគណនីចរន្តរបស់អ្នកទទួលសេវា នៅសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ក្នុងខេត្តតែមួយ។

សេចក្ដីដូចបានជម្រាបជូន សូមក្រសួង-ស្ថាប័នរដ្ឋ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលប្រើប្រាស់សេវាធនាគារតាមប្រព័ន្ធអេឡិចត្រូនិក (OBS) មេត្តាជ្រាបជាព័ត៌មាន។


**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៧២២ ៥៦៣ (Ext. ១០៥២)
អ៊ីម៉ែល ៖ nbcobs@nbc.org.kh


**បណ្ដាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.org.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA